COPY

The king wrote a letter to his son Ranariddh who just got a new position as a president of natonal assembly

ព្រះករុណាព្រះបាទសម្តេច
ព្រះនរោត្តម សីហនុ
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ
ប្រធានរដ្ឋសភាជាតិ
ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចក្រុមព្រះជាទីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់បំផុត

ខ្ញុំបានទទួលរួចហើយលិខិតចុះថ្ងៃទី២៥ ខែវិច្ឆិកា របស់សម្តេចក្រុមព្រះ ស្តីអំពីលទ្ធផលនៃអង្គប្រជុំរដ្ឋសភា នាថ្ងៃនេះ ។

ខ្ញុំសូមអរព្រះគុណ និងសូមសំដែងនូវការកោតសរសើរ ព្រមទាំងស្នេហាដ៏ជ្រាលជ្រៅ ជាទីបំផុត ចំពោះជោគជ័យរបស់សម្តេចក្រុមព្រះ និងការប្តេជ្ញាហច្ចន័យដើម្បីបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តមជូនជាតិ ក្នុងឋានៈជាប្រធានរដ្ឋសភាជាតិយើង ។

ខ្ញុំសូមជូនពរសម្តេចក្រុមព្រះ និងសមាជិក សមាជិកាដ៏ឧត្តុង្គឧត្តមទាំងអស់នៃរដ្ឋសភាជាតិយើង ទទួលបាននូវមហាជោគជ័យក្នុងបេសកកម្មជាប្រវត្តិសាស្ត្ររបស់ប្រជាជាតិយើង ព្រមទាំងប្រកបតែនឹងពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណ សុខ ពល និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសម្តេចក្រុមព្រះ ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំ ។

នរោត្តម សីហនុ

ប៉េកាំង ថ្ងៃទី២៥ ខែវិច្ឆិកា ១៩៩៨